# អនុក្រឹត្យលេខ ១៩៧ អនក្រ.បក ចុះថ្ងៃទី២៩/០៨/២០១១
# ស្តីពីការកំណត់ដែនប្រៃលិចទឹកចំនួន ៦៤៧ ៤០៦ ហិកតា ស្ថិតនៅក្នុងខេត្តទាំង ៦ ជុំវិញបឹងទន្លេសាប (ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប និងខេត្តកំពង់ធំ)

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការការពារបរិស្ថាន នងិការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៦ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៣០ ចុះថ្ងៃទី១០ ខែមេសា ២០០១ ស្តីពីការបង្កើត និងគ្រប់គ្រងបបនីយជីវៈមណ្ឌលបឹងទន្លេសាប
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៣០៥ ចុះថ្ងៃទី២៩ ខែមិថុនា ២០០៩ ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១០/២៥៨ ចុះថ្ងៃទី២៤ ខែមីនា ២០១០ ស្តីពីការកែសម្រួលមាត្រា ៥ មាត្រា ៦ មាត្រា ៩ មាត្រា ១០ និងមាត្រា ១២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៣០៥ ចុះថ្ងៃទី២៩ ខែមិថុនា ២០០៩ ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប
- បានឃើញការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

### មាត្រា ១.-

ត្រូវបានកំណត់ដែលព្រៃលិចទឹកនៅជុំវិញបឹងទន្លេសាប ស្ថិតនៅភូមិសាស្ត្រខេត្តកំពង់ឆ្នាំង

ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប និងខេត្តកំពង់ធំ ដែលមានផ្ទៃដីសរុបចំនួន ៦៤៧ ៤០៦ ហិកតា រួមមាន ៨០២ ចំណុច ដូចមានក្នុងឧបសម្ពន្ធ ១ នៃអនុក្រឹត្យនេះ ។

មាត្រា ២.-

ផែនទីដែនព្រៃលិចទឹក (ដោយមានភ្ជាប់ជូនទាំងនិយាមកា) ក្នុងខេត្តទាំងប្រាំមួយខាងលើ ជាឧបសម្ពន្ធ ២ នៃអនុក្រឹត្យនេះ ។

មាត្រា ៣.-

អំពីភារកិច្ច កាតព្វកិច្ច និងការទទួលខុសត្រូវលើការគ្រប់គ្រង ការការពារ និងការថែរក្សាដែនព្រៃលិចទឹក និងព្រៃលិចទឹក ៖

- អភិបាលនៃគណៈអភិបាលខេត្តទាំងប្រាំមួយជុំវិញបឹងទន្លេសាបរួមមាន ៖ ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប និងខេត្តកំពង់ធំ មានភារកិច្ច កាតព្វកិច្ច និងការទទួលខុសត្រូវលើការគ្រប់គ្រង ការការពារ ថែរក្សាដែនព្រៃលិចទឹក និងព្រៃលិចទឹកដូចខាងក្រោម ៖

១- មានភារកិច្ចគ្រប់គ្រងដោយផ្ទាល់លើដែនព្រៃលិចទឹកដែលមាននៅក្នុងខេត្តនីមួយៗ ។

២- មានកាតព្វកិច្ចការពារឱ្យខាងតែបាននូវដែនព្រៃលិចទឹក និងព្រៃលិចទឹកដែលមាននៅក្នុងខេត្តនីមួយៗ ។

៣- ការបាត់បង់ដែនព្រៃលិចទឹក និងព្រៃលិចទឹកដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចនៃខេត្តណា គណៈអភិបាលនៃខេត្តត្រូវទទួលខុសត្រូវទាងស្រុងចំពោះមុខរាជរដ្ឋាភិបាល ។

- រដ្ឋបាលជលផលត្រូវធ្វើការត្រួតពិនិត្យជាប្រចាំលើសកម្មភាពថែរក្សាការពារដែនព្រៃលិចទឹក និងព្រៃលិចទឹករបស់អាជ្ញាធរខេត្តទាំង០៦ខាងលើ និងត្រូវចាត់វិធានការតាមច្បាប់ជាបន្ទាន់ក្នុងករណីពិនិត្យឃើញថាមានសកម្មភាពដែលនាំឱ្យប៉ះពាល់ដល់ដែនព្រៃលិចទឹក និងព្រៃលិចទឹក ។

- អាជ្ញាធរទន្លេសាបមានភារកិច្ចធ្វើអធិការកិច្ចលើគ្រប់សកម្មភាពពាក់ព័ន្ធនឹងដែនព្រៃលិចទឹក និងព្រៃលិចទឹក និងត្រូវធ្វើសេចក្តីរាយការណ៍ពីសកម្មភាពទាំងនោះជូននាយករដ្ឋមន្ត្រី ដើម្បីមានវិធានការវិធានការសម្រេច ។

មាត្រា ៤.-

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧត្តុនិយម រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រធានអាជ្ញាធរទន្លេសាប រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន អភិបាលនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប និងខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល ៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៥ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ